ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# ដោយលើកឡើងពីការព្រួយបារម្ភអំពីបរិយាកាសនៃការបោះឆ្នោត សមាជិកសភាអាស៊ានអំពាវនាវឱ្យមានការបោះឆ្នោត ដោយសន្តិវិធី និងបើកចំហ នៅក្នុងប្រទេសកម្ពុជា

ទីក្រុងបាងកក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ - មុនការបោះឆ្នោតថ្នាក់មូលដ្ឋាននៅប្រទេសកម្ពុជា ដែលគ្រោងរៀបចំនៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនាខាងមុខនេះ សមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) សូមអំពាវនាវឱ្យបញ្ចប់ការគំរាមកំហែង អំពើហិង្សា និងការបំភិតបំភ័យ និងសុំឲ្យអាជ្ញាធរធានាថា សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនដែលជាជម្រើសរបស់ពួកគេ ត្រូវបានការពារ។

ក្រុមសមាជិកសភាក្នុងតំបន់ សម្តែងនូវការព្រួយបារម្ភចំពោះការគំរាមកំហែងពីអំពើហិង្សា ម្តងហើយម្តងទៀត ដែលធ្វើឡើងដោយសមាជិកជាន់ខ្ពស់របស់គណបក្សកាន់អំណាចមុនការបោះឆ្នោត ដែលពួកគេបានអះអាងថាបង្កើតឱ្យមានបរិយាកាសនៃការភ័យខ្លាច ដែលបានបំផ្លាញរួចទៅហើយនូវការរំពឹងទុកចំពោះការបោះឆ្នោតដោយសេរី និងត្រឹមត្រូវពិតប្រាកដ។

លោក Charles Santiago ប្រធានសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស និងជាសមាជិកសភាប្រទេសម៉ាឡេស៊ី បានថ្លែងថា "ប្រជាពលរដ្ឋកម្ពុជាសមនឹងទទួលបានឱកាសក្នុងការជ្រើសរើសមេដឹកនាំនៅមូលដ្ឋានរបស់ខ្លួនដោយគ្មានការភ័យខ្លាច។ ខណៈពេលដែលមានរបាយការណ៍ជាច្រើនពីការគំរាមកំហែង វាមិនអាចទៅរួចទេ ដែលមិនមានការព្រួយបារម្ភអំពីការបោះឆ្នោត នៅថ្ងៃអាទិត្យខាងមុខនេះ។ បរិយាកាសនយោបាយអាប់អួដែលពួកគេបានបង្កឡើង គឺមិនអំណោយផលដល់ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវឡើយ។"

លោកបន្តថា "ការកើនឡើងនៃការគាបសង្កត់ និងការរឹតត្បិត សិទ្ធិ និងបរិយាកាសនយោបាយ នៅកម្ពុជា និងគ្រោះថ្នាក់ និងផលប៉ះពាល់នៃភាពបរាជ័យនៃលទ្ធិប្រជាធិបតេយ្យនៅទីនោះ ធ្វើឱ្យវាក្លាយជាស្ថានភាពបន្ទាន់បំផុតមួយនៅក្នុងតំបន់របស់យើង។ យើងទាំងអស់គ្នាចាំបាច់ត្រូវឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ចំពោះអ្វីដែលកើតឡើងក្នុងអំឡុងពេលថ្ងៃចុងសប្តាហ៍នេះ។ អាជ្ញាធរត្រូវតែធានាឱ្យបាន ដោយមិនមានការខកខានថា គ្មានអ្វីកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការបោះឆ្នោតដោយឯករាជ្យរបស់ប្រជាពលរដ្ឋនោះទេ។ ការនេះគួរតែរួមបញ្ចូលនូវការណែនាំយ៉ាងច្បាស់លាស់ដល់អាជ្ញាធរមូលដ្ឋានថា គ្មានករណីនៃការបំភិតបំភ័យដល់អ្នកបោះឆ្នោត ជាពិសេសនៅតាមការិយាល័យបោះឆ្នោត នឹងត្រូវបានអត់ឱននោះទេ។"

សមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស បានទាញការយកចិត្តទុកដាក់ចំពោះការរកឃើញនៃរបាយការណ៍នាពេលថ្មីៗនេះរបស់ខ្លួនអំពី ការស្លាប់នៃលទ្ធិប្រជាធិបតេយ្យ៖ ការវាយប្រហារទៅលើសមាជិកសភា និងការគំរាមកំហែងចំពោះស្ថាប័នរបស់ប្រទេសកម្ពុជា និងការបរាជ័យរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងបញ្ហា និងអនុសាសន៍ដែលត្រូវបានលើកឡើង។ របាយការណ៍ដែលចេញផ្សាយនៅក្នុងខែមីនា បានរៀបរាប់លម្អិតអំពីការប្រើប្រាស់ការគំរាមកំហែងពីអំពើហិង្សា ម្តងហើយម្តងទៀត ដើម្បីបំផ្លាញគណបក្សប្រឆាំង

និងដើម្បីរឹតបន្តឹងបន្ថែមទៀតនូវលំហរបស់សង្គមស៊ីវិល ព្រមទាំងផលប៉ះពាល់នៃការគំរាមកំហែងទាំងនេះចំពោះអនាគតនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។

សមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស ថ្លែងថា ចាប់តាំងពីការចេញផ្សាយរបាយការណ៍នេះ ការប្រើប្រាស់ការគំរាមកំហែងរបស់រដ្ឋាភិបាល បានបន្តដែលក្នុងនោះរួមមានទាំង ក្នុងអំឡុងពេលយុទ្ធនាការឃោសនា ដូចជាការគំរាមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី២៥ ខែឧសភា "ក្នុងការបង្កសង្គ្រាម" ទៅលើគណបក្សប្រឆាំងប្រសិនបើគណបក្សកាន់អំណាចត្រូវ "បាត់បង់ការអត់ធ្មត់"។ រដ្ឋមន្ត្រីក្រសួងការពារជាតិលោក ទៀ បាញ់ ក៏បានព្រមាននាពេលថ្មីៗនេះផងដែរថា កងកម្លាំងយោធាអាចត្រូវបានប្រើប្រាស់ដើម្បីបង្ក្រាបលើការតវ៉ាដែលអាចកើតមានក្រោយការបោះឆ្នោត ហើយថាក្រុមអ្នកតវ៉ានឹងត្រូវបាន "វាយរហូតដល់បាក់ធ្មេញ" ដែលនេះជាការរំលោភច្បាប់ជាតិ ដែលចែងថា កម្លាំងប្រដាប់អាវុធគួរនៅអព្យាក្រឹត។

លោក Santiago ថ្លែងថា "ការបោះឆ្នោតថ្នាក់មូលដ្ឋាននៅថ្ងៃអាទិត្យខាងមុខនេះមានសារសំខាន់ណាស់សម្រាប់ប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន ហើយការបោះឆ្នោតនេះត្រូវបានមើលឃើញដោយមនុស្សជាច្រើនថាជាការធ្វើតេស្តលម្អិតមួយ អំពីបរិយាកាសនយោបាយមុនការបោះឆ្នោតថ្នាក់ជាតិ ដែលត្រូវបានគ្រោងរៀបចំនៅឆ្នាំ២០១៨។ វាសឹងតែដូចជា រដ្ឋាភិបាលបានព្យាយាមបង្ហាញពីចំណុចរបស់យើងទៅហើយ។ ជំនួសឱ្យការបន្ថយការប្រើវោហាសាស្ត្រពីអំពើហិង្សា មន្ត្រីជាន់ខ្ពស់គណបក្សកាន់អំណាច រួមទាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្តចុះទៅកាន់ផ្លូវគ្រោះថ្នាក់ ដែលគំរាមកំហែងដល់ការរំពឹងទុកនូវការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅថ្ងៃអាទិត្យខាងមុខ។"

លោក Santiago បានបន្ថែមថា "និយាយឲ្យចំ កុំពង្វាងវែងឆ្ងាយនៅទីនេះ អនាគតនៃលទ្ធិប្រជាធិបតេយ្យដ៏ផុយស្រួយរបស់ប្រទេសកម្ពុជា គឺស្ថិតនៅក្រោមការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរខ្លាំងណាស់។ គណបក្សកាន់អំណាចមានភាពប្រាកដច្បាស់ណាស់ថា៖ ការបរាជ័យរបស់រដ្ឋាភិបាលនៅក្នុងប្រអប់ឆ្នោតនៅក្នុងការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំក្រោយ នឹងមិនត្រូវបានទទួលយក ហើយអាចនឹងកើតមានអំពើហិង្សាប្រសិនបើចាំបាច់។ វោហាសាសន៍អំពីអំពើហិង្សា និងការធ្វើរដ្ឋប្រហារនេះ មិនមែនគ្រាន់តែជាការគំរាមកំហែងដល់គណបក្សប្រឆាំងនោះទេ តែវាក៏ជាការបំភិតបំភ័យប្រជាពលរដ្ឋកម្ពុជាជារៀងរាល់ថ្ងៃ ដើម្បីឲ្យបោះឆ្នោតឲ្យគណបក្សកាន់អំណាច និងជាការកំណត់នូវបំណងប្រាថ្នារបស់ខ្លួនសម្រាប់ការផ្លាស់ប្តូរ។ លទ្ធិប្រជាធិបតេយ្យគឺនិយាយអំពីការអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើការជ្រើសរើសដោយខ្លួនឯងផ្ទាល់នៅក្នុងប្រអប់ឆ្នោត មិនមែនអំពីការគំរាមកំហែងពួកគេជាមួយនឹងអំពើហិង្សា ប្រសិនបើពួកគេមិនបានធ្វើតាមការណែនាំរបស់អ្នកនោះទេ។"

ក្រៅពីការគំរាមកំហែងរបស់មន្ត្រីរដ្ឋាភិបាលពីអំពើហិង្សា ក៏មានការលើកឡើងនូវការព្រួយបារម្ភពាក់ព័ន្ធនឹងនីតិវិធីនៃការបោះឆ្នោតផងដែរ។ទាំងនេះរួមបញ្ចូលទាំងរបាយការណ៍ដែលថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបោះពុម្ពសន្លឹកឆ្នោតលើស២០ភាគរយច្រើនជាងការចាំបាច់ និងថាទឹកខ្មៅដែលប្រើដើម្បីកំណត់អត្តសញ្ញាណប្រជាពលរដ្ឋដែលបានបោះឆ្នោតរួចហើយអាចត្រូវបានលាងជ្រះយ៉ាងងាយស្រួល។

លោក Tom Villarin សមាជិកសភាប្រទេសហ្វីលីពីន បានថ្លែងថា "ដោយផ្អែកលើរបាយការណ៍ប្រកបដោយការព្រួយបារម្ភទាំងនេះ អាជ្ញាធរនៅក្នុងប្រទេសកម្ពុជាត្រូវតែធានាឱ្យបានថា នីតិវិធីទាំងអស់ដែលប្រគល់សិទ្ធិឱ្យដោយបទប្បញ្ញត្តិ និងច្បាប់ជាតិ ត្រូវបានអនុវត្តយ៉ាងតឹងរឹង និងធានាថា អ្នកឃ្លាំមើលការបោះឆ្នោតអាចសង្កេតមើលទាំងការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត ដោយគ្មានការរារាំង ណាមួយនោះទេ។ នេះគឺជាវិធីតែមួយគត់ដើម្បីធានាថា ប្រជាពលរដ្ឋកម្ពុជាអាចជឿទុកចិត្តលើលទ្ធផលនៃការបោះឆ្នោតនោះបាន។"

អាជ្ញាធរកម្ពុជាក៏បានបង្កឧបសគ្គមួយចំនួនដល់ការខិតខំប្រឹងប្រែងក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សប្រឆាំង។ មន្ត្រីរដ្ឋាភិបាលបានបដិសេធចំពោះការអនុញ្ញាតសម្រាប់ការប្រមូលផ្តុំ និងការធ្វើបាតុកម្ម និងបានប្រានចោលនូវពាក្យស្លោក និងសម្ភារដទៃទៀតសម្រាប់យុទ្ធនាការឃោសនា តាមអំពើចិត្ត និងភាគច្រើនដោយគ្មានយុត្តិកម្មតាមផ្លូវច្បាប់ណាមួយ ព្រមទាំងមានការរំលោភបំពានយ៉ាងច្បាស់នូវសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំ ដែលធានាដោយរដ្ឋធម្មនុញ្ញ។

ក្រុមសមាជិកសភាអះអាងថា ការវិវត្តន៍ទាំងនេះបានធ្វើឱ្យការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅថ្ងៃអាទិត្យខាងមុខនេះ កាន់តែត្រូវយកមកពិភាក្សាដោះស្រាយជាបន្ទាន់ ហើយការបោះឆ្នោតដោយបើកចំហ និងសន្តិវិធីនឹងដើរឆ្ពោះទៅរកការកំណត់ប្រទេសកម្ពុជា ឲ្យនៅលើផ្លូវត្រឹមត្រូវជាថ្មីម្តងទៀត។

លោក Villarin បានថ្លែងថា "ការបោះឆ្នោតនៅថ្ងៃអាទិត្យខាងមុខនេះ គឺជាឱកាសមួយមិនគ្រាន់តែសំរាប់ប្រជាពលរដ្ឋកម្ពុជាដែលបោះឆ្នោតនោះទេ ប៉ុន្តែក៏សម្រាប់គណបក្សប្រជាជនកម្ពុជា ក្នុងការបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីលទ្ធិប្រជាធិបតេយ្យ។ រហូតមកដល់ពេលនេះ សកម្មភាពរបស់អាជ្ញាធរបានកំពុងផ្ញើសារយ៉ាងច្បាស់រួចទៅហើយថា លទ្ធិប្រជាធិបតេយ្យ គឺមិនស្ថិតនៅលំដាប់កំពូលនៃបញ្ជីអាទិភាពរបស់ពួកគេនោះទេ។"

លោក Villarin ថ្លែងបន្ថែមថា "នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ យើងបានឃើញសំណឹករិចរិលនៃលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែឃើញយ៉ាងច្បាស់ថា ប្រទេសកម្ពុជាហាក់ដូចជាកំពុងរត់ចុះទៅតាមផ្លូវនេះយ៉ាងលឿនជាងប្រទេសដទៃផ្សេងទៀត។ វាមានផលវិបាកធ្ងន់ធ្ងរយូរអង្វែងមិនមែនតែចំពោះប្រជាពលរដ្ឋកម្ពុជានោះទេ ប៉ុន្តែចំពោះតំបន់ទាំងមូលផងដែរ។"

លោក Charles Santiago បានថ្លែងថា "ការបោះឆ្នោតទាំងនេះរួមជាមួយនឹងការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំក្រោយនេះ តំណាងឲ្យឱកាសដើម្បីបង្ហាញទៅប្រទេសដទៃទៀតនៃអាស៊ានថា ប្រទេសកម្ពុជាត្រៀមខ្លួនជាស្រេច ក្នុងការប្តេជ្ញាចិត្តចំពោះកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន និងនាំមុខគេក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅទូទាំងតំបន់នេះ។ ពិភពលោកនឹងឃ្លាំមើលនៅថ្ងៃអាទិត្យខាងមុខនេះ ហើយគណបក្សប្រជាជនកម្ពុជាគួរតែដឹងថា យើងគាំទ្រប្រជាជនកម្ពុជា និងបំណងប្រាថ្នាប្រជាធិតេយ្យរបស់ពួកគេ»។